PHNOM PENH WATER SUPPLY AUTHORITY

# របាយការណ៍ចីរភាពប្រចាំឆ្នាំ២០២៤







# មាតិកា


សេចក្តីថ្លែងរបស់អគ្គនាយក ........ i
ទស្សនវិស័យ ........ ១
បេសកកម្ម ........ ១
ដំណើរការប្រព្រឹត្តកម្ម និងផ្គត់ផ្គង់ទឹកស្អាត នៃ រ.ទ.ស.ភ ........ ១
ការគ្រប់គ្រងប្រកបដោយចីរភាព និងអនុលោមភាព ........ ២
ព័ត៌មាន តារាង «ក» ........ ៤
ព័ត៌មានប្រតិបត្តិការ ........ ៤
អភិបាលកិច្ចប្រកបដោយចីរភាព ........ ៤
ផលប៉ះពាល់សង្គម ........ ៥
ផលប៉ះពាល់បរិស្ថាន ........ ៨
ផលប៉ះពាល់អាកាសធាតុ ........ ៩



ឯកឧត្តម ឡុង ណារ៉ូ
អគ្គនាយក

# សេចក្តីថ្លែងរបស់

## ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រ.ទ.ស.ភ ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាល ក្រសួងអាណាព្យាបាល និងក្រុមប្រឹក្សាភិបាល បានធ្វើឱ្យ រ.ទ.ស.ភ អាចធ្វើការអភិវឌ្ឍន៍ខ្លួនយ៉ាងខ្លាំងក្លាក្នុងការពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។ ផ្អែកតាមបច្ចុប្បន្នភាពផែនការមេដំណាក់កាលទី៣ (២០២១-២០៣០) របស់ខ្លួន រ.ទ.ស.ភ បានបន្តខិតខំសហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីឈានទៅអនុវត្តគម្រោងពង្រីកសមត្ថភាពផលិតកម្ម និងផ្គត់ផ្គង់ទឹក ក្នុងគោលបំណងចូលរួមចំណែកសម្រេចឱ្យបាននូវគោលដៅទី ៦ ស្តីពី "ទឹកស្អាត និងអនាម័យ" នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏ដូចជាគោលដៅយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ លើការងារផ្គត់ផ្គង់ទឹកស្អាតនៅឆ្នាំ ២០៣០។

នៅក្នុងឆ្នាំ២០២៤ រ.ទ.ស.ភ បានសម្រេចនូវសមិទ្ធផលជាផ្លែផ្កាក្នុងការដាក់ឱ្យដំណើរការជាផ្លូវការនូវរោងចក្រប្រព្រឹត្តកម្មទឹកស្អាតថ្មីចំនួន ២ គឺរោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំហានទី២ និងរោងចក្រប្រព្រឹត្តកម្មទឹកស្អាតបឹងធំ ដែលធ្វើឱ្យ រ.ទ.ស.ភ អាចបង្កើនសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតកើនឡើងរហូតដល់ ៩៨៨ពាន់ម៉ែត្រគូបក្នុងមួយថ្ងៃ។ ការដាក់ឱ្យដំណើរការរោងចក្រប្រព្រឹត្តកម្មទឹកស្អាតបឹងធំនៅក្នុងឆ្នាំ២០២៤នេះ គឺជាសមិទ្ធផលដ៏សំខាន់ និងផ្តល់ផលប្រយោជន៍យ៉ាងខ្លាំងដល់ប្រជាពលរដ្ឋចំនួន ១០ភូមិ ដែលស្ថិតនៅក្នុងសង្កាត់ប្រទះឡាង សង្កាត់បឹងធំ និងសង្កាត់ពងទឹក នៃខណ្ឌកំបូល ប្រមាណជា ៣.០០០គ្រួសារ ដែលអាចទទួលបានទឹកស្អាតប្រើប្រាស់លឿនជាងផែនការដែលបានកំណត់ ព្រោះថាប្រសិនបើពុំមានគម្រោងនេះទេ ប្រជាពលរដ្ឋដែលរស់នៅភូមិសាស្ត្រដែលបានលើកឡើងនេះ បើយោងតាមផែនការមេរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំទាន់អាចទទួលបានទឹកស្អាតដែលផ្គត់ផ្គង់ដោយ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបាននាខណៈនេះទេ ដោយត្រូវរង់ចាំរហូតដល់ប៉ុន្មានឆ្នាំខាងមុខ។ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំហានទី ២ ជារោងចក្រថ្មីដែលបានបំពាក់នូវប្រព័ន្ធសូឡាដែលមានអានុភាពសរុប ១,៩ មេហ្គាវ៉ាត់ បន្ថែមពីលើរោងចក្រផ្សេងៗដែលបានបំពាក់ប្រព័ន្ធសូឡានាពេលកន្លងមកដូចជា រោងចក្រប្រព្រឹត្តកម្មទឹកស្អាតភូមិព្រែក (មានអានុភាពសរុបប្រមាណ ៧៧៩ គីឡូវ៉ាត់) និងរោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំហានទី១ (មានអានុភាពសរុប ១,៩ មេហ្គាវ៉ាត់) ក្នុងន័យចូលរួមចំណែកក្នុងការការពារបរិស្ថានតាមរយៈការប្រើប្រាស់ថាមពលស្អាត និងសន្សំសំចៃថាមពលដែលឈានទៅដល់ការកាត់បន្ថយក្នុងការបំភាយឧស្ម័នកាបូនិចទៅក្នុងបរិយាកាស។

ទន្ទឹមនឹងនេះ ការធ្វើប្រព្រឹត្តកម្មទឹកស្អាតរបស់ រ.ទ.ស.ភ គឺបានអនុលោមតាមស្តង់ដារគុណភាពទឹកផឹកថ្នាក់ជាតិ និង ស្តង់ដារគុណភាពទឹកផឹករបស់អង្គការសុខភាពពិភពលោក (WHO) ដោយមានបន្ទប់ពិសោធន៍គុណភាពទឹកសម្រាប់ធ្វើការវិភាគ ជាមួយគ្នានេះយើងតែងតែបានធ្វើការវិភាគគុណភាពទឹកជាមួយនឹងមន្ទីរពិសោធន៍ក្រៅប្រទេស (មន្ទីរពិសោធន៍សិង្ហបុរី និងសៀងហៃ) ផងដែរ។ ការយកចិត្តទុកដាក់ និងតាមដានគុណភាពទឹកជាប្រចាំនេះ អាចអនុញ្ញាតឱ្យ រ.ទ.ស.ភ អាចធានាជូនដល់អតិថិជនបាននូវទឹកស្អាតដែលអាចផឹកដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ ដើម្បីធានាបាននូវពាក្យស្លោក **"ទឹកស្អាតសម្រាប់អ្នកទាំងអស់គ្នា"** និងផ្តល់ការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាព អនាម័យ និងនិរន្តរភាព ដើម្បីការរស់នៅប្រកបដោយសុខុមាលភាព មានជីវភាពល្អប្រសើរ និងមានបរិស្ថានល្អ។

ក្រៅពីនេះ អង្គភាពបានចូលរួមចំណែកដល់សកម្មភាពសង្គមជាច្រើនដូចជា ការទទួលខុសត្រូវចំពោះមន្ត្រី-និយោជិត (តាមរយៈការបណ្តុះបណ្តាល, ការបង់វិភាគទានរបបសន្តិសុខសង្គម ។ល។) ការបរិច្ចាគថវិកាជូនកាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ការឧបត្ថម្ភដល់មូលនិធិគន្ធបុប្ផាកម្ពុជា, ការផ្គត់ផ្គង់ទឹកតាមបង្គោលអគ្គីភ័យជាដើម។ លើសពីនេះ ដើម្បីចូលរួមចំណែកអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា រ.ទ.ស.ភ បានចាប់ផ្តើមអនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតជូនដល់គ្រួសារមានចំណូលទាប ចាប់តាំងពីឆ្នាំ១៩៩៩ មកម្លេះ។

លើសពីនេះ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ រ.ទ.ស.ភ ក៏បានអនុវត្តកម្មវិធីកាត់បន្ថយអត្រាទឹកគ្មានចំណូល (NRW), Mobile App កំពុងអនុវត្តគម្រោងគ្រប់គ្រងបណ្តាញទឹកស្អាត តាមបច្ចេកវិទ្យាវៃឆ្លាត, គម្រោង Asset Management & Maintenance System និងព្រមទាំងបានបំពាក់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យនៅតាមបណ្តារោងចក្រមួយចំនួន ដែលជួយឱ្យអង្គភាពសន្សំសំចៃថាមពល និងកាត់បន្ថយការបំភាយឧស្ម័នកាបូនិច។

រ.ទ.ស.ភ មានសេចក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីរាជរដ្ឋាភិបាលក៏ដូចជាអាណាព្យាបាលទាំងពីរគឺ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសូមសម្តែងនូវអំណរគុណដល់ក្រុមប្រឹក្សាភិបាលចំពោះការគាំទ្រ និងផ្តល់នូវចក្ខុវិស័យយ៉ាងល្អដល់ រ.ទ.ស.ភ។ ទន្ទឹមនឹងនេះ យើងក៏សូមថ្លែងអំណរគុណដល់បណ្តាដៃគូអភិវឌ្ឍន៍ និងគ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួមចំណែកយ៉ាងសំខាន់ជាមួយ រ.ទ.ស.ភ ក្នុងការអភិវឌ្ឍន៍នូវសមត្ថភាពក្នុងការផលិត និងផ្គត់ផ្គង់ទឹកស្អាត។ ជាចុងក្រោយ សូមថ្លែងអំណរគុណជូនចំពោះអតិថិជនទាំងអស់ដែលបានគាំទ្រធ្វើឱ្យ រ.ទ.ស.ភ បានទទួលជោគជ័យដូចសព្វថ្ងៃនេះ។

ថ្ងៃសុក្រ ៧កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយកនៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**ឡុង ណារ៉ូ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

«**រ.ទ.ស.ភ**»

# របាយការណ៍ចីរភាពប្រចាំឆ្នាំ២០២៤

## ទស្សនវិស័យ

រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឱ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សា ជាអ្នកសម្របសម្រួលដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជន ខេត្ត-ក្រុង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោក មានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។

## បេសកកម្ម

បេសកកម្មរបស់ រ.ទ.ស.ភ គឺធានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ម៉ោង លើ ២៤ម៉ោង ក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់ និងរាជធានីភ្នំពេញដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ។ ក្រៅពីនេះ រ.ទ.ស.ភ បាននឹងកំពុងចែករំលែកបទពិសោធន៍ការងាររបស់ខ្លួនដល់បណ្តារដ្ឋាករទឹកខេត្ត-ក្រុងមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជាព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោកតាមសំណូមពរសំដៅសម្រេចអោយបាននូវ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (CSDGs)។

## ដំណើរការប្រព្រឹត្តកម្ម និងផ្គត់ផ្គត់ទឹកស្អាត នៃ រ.ទ.ស.ភ

នៅក្នុងឆ្នាំ ២០២៤ រ.ទ.ស.ភ បានផ្គត់ផ្គត់ទឹកស្អាតជូនប្រជាពលរដ្ឋនៅក្នុងផ្ទៃសេវារបស់ខ្លួន ចេញពីរោងចក្រប្រព្រឹត្តកម្មទឹកស្អាតសរុបចំនួន ៦ ដែលប្រើប្រាស់ប្រភពទឹកចេញពីទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ និងស្ទឹងព្រែកត្នោត ដែលមានសមត្ថភាពផលិតទឹកស្អាតជាមធ្យមសរុប ៩៨៨ពាន់ម៉ែត្រគូបក្នុងមួយថ្ងៃ។ ក្នុងដំណើរប្រព្រឹត្តកម្មទឹកស្អាតនេះ រ.ទ.ស.ភ បានប្រើប្រាស់ PAC ក្ល័រ និងកំបោរ ដើម្បីអាចធានាបាននូវគុណភាពទឹកស្អាតស្តង់ដារគុណភាពទឹកផឹកថ្នាក់ជាតិ និង ស្តង់ដារគុណភាពទឹកផឹករបស់អង្គការសុខភាពពិភពលោក (WHO)។ តាមរយៈការផ្គត់ផ្គង់ទឹកស្អាតចេញពីរោងចក្រប្រព្រឹត្តកម្មទឹកស្អាតទាំង ៦ បានធ្វើឱ្យសម្ពាធទឹកសម្រាប់អតិថិជននៅចុងបណ្តាញអាចទទួលបានទឹកស្អាតក្នុងសម្ពាធទឹកប្រមាណពី ១,៥ ទៅ ២បារ។

ខាងក្រោមនេះ ជារូបភាពតំណាងនៃដំណើរការប្រព្រឹត្តកម្មទឹកស្អាតសម្រាប់បណ្ដាញចែកចាយរបស់ រ.ទ.ស.ភ៖

### ខ្សែសង្វាក់ប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ




## ការគ្រប់គ្រងប្រកបដោយចីរភាព និងអនុលោមភាព



### ធានាគុណភាពទឹក ១០០%

ការវិភាគគុណភាពទឹកបំពេញតាមស្តង់ដារគុណភាពទឹកផឹកថ្នាក់ជាតិ និងការណែនាំអំពីទឹកផឹករបស់អង្គការសុខភាពពិភពលោក




### ការកាត់បន្ថយការបំភាយឧស្ម័នកាបូនិច

រ.ទ.ស.ភ បាននឹងកំពុងប្រើប្រាស់ថាមពលស្អាតតាមរយៈការប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យក្នុងដំណើរការប្រតិបត្តិការ ដើម្បីចូលរួមក្នុងការកាត់បន្ថយការបំភាយឧស្ម័នកាបូនិច

### អត្រាប្រមូលវិក្កយបត្រថ្លៃទឹក ៩៩,៩០%



រ.ទ.ស.ភ បានប្រើប្រាស់ប្រព័ន្ធ Spot Billing ក្នុងការអានលេខ និងចេញវិក្កយបត្រថ្លៃទឹកស្អាតនៅទីកន្លែងផ្ទាល់ ដើម្បីធានាបាននូវប្រសិទ្ធភាព និងទិន្នផលកាន់តែប្រសើរលើការងារប្រមូលប្រាក់ថ្លៃទឹកពីអតិថិជន។

បន្ថែមពីលើនេះទៀត អតិថិជនរបស់ រ.ទ.ស.ភ អាចធ្វើការទូទាត់ប្រាក់ដោយផ្ទាល់នៅតាមសាខាទទួលប្រាក់ថ្លៃទឹកទាំង៦កន្លែង រួមទាំងដៃគូសហការទូទាត់តាមអនឡាញរបស់ រ.ទ.ស.ភ។

## ការគ្រប់គ្រងប្រកបដោយចីរភាព និងអនុលោមភាព

រ.ទ.ស.ភ បាន និងកំពុង ខិតខំប្រឹងប្រែងផលិតទឹកស្អាតប្រកបដោយគុណភាព និងសុវត្ថិភាពជូនប្រជាពលរដ្ឋដែលប្រើប្រាស់ទឹកស្អាត រ.ទ.ស.ភ ។ ដើម្បីទទួលបានទំនុកចិត្តបន្ថែមពីប្រជាពលរដ្ឋ រ.ទ.ស.ភ បានបញ្ជូនទឹកគំរូសាកដែលចេញពីរោងចក្រផលិតទឹកស្អាតបាក់ខែងទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ឯករាជ្យ TUV SUD PSB Pts Ltd. នៃប្រទេសសិង្ហបុរី ដែលមាន មុខវិភាគចំនួន ១២៦មុខ *(លម្អិតក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២៤ ទំព័រ២៩)*


រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ និងជំហានទី២


ថាមពលស្អាតដែលផលិតចេញពីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ

រ.ទ.ស.ភ បានបំពាក់ប្រព័ន្ធថាមពលស្អាតដែលបានផលិតចេញពីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ តាមបណ្តារោងចក្រប្រព្រឹត្តកម្មទឹកស្អាតរបស់ខ្លួនមួយចំនួន។ ប្រព័ន្ធនេះត្រូវបានប្រើប្រាស់ស្របគ្នា ជាមួយនឹងថាមពលអគ្គិសនីដែលបានផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា (ELECTRICITÉ DU CAMBODGE)។

រ.ទ.ស.ភ បានប្រើប្រាស់ប្រព័ន្ធ Spot Billing ក្នុងការអានលេខ និងចេញវិក្កយបត្រថ្លៃប្រើប្រាស់ទឹកស្អាត ដើម្បីធានាបាននូវប្រសិទ្ធភាព និងទិន្នផលកាន់តែប្រសើរលើការងារប្រមូលប្រាក់ថ្លៃទឹកពីអតិថិជន។


ការអានលេខ និងចេញវិក្កយបត្រដោយប្រើប្រព័ន្ធ Spot Billing



ដៃគូសហការក្នុងទូទាត់វិក្កយបត្រថ្លៃប្រើប្រាស់ទឹកស្អាតរបស់ រ.ទ.ស.ភ

អតិថិជនអាចធ្វើការទូទាត់វិក្កយបត្រថ្លៃប្រើប្រាស់ទឹកស្អាតកាន់តែឆាប់រហ័ស និងមានភាពងាយស្រួលជាមួយសេវាទូទាត់អេឡិចត្រូនិចតាមរយៈ PPWSA APP, ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភ្នាក់ងារវេរសាច់ប្រាក់។

# តារាង «ក»

| | | |
|---|---|---|
| **ព័ត៌មានប្រតិបត្តិការ** | | |
| ១ | គំរូអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ | មានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០២៤ របស់ រ.ទ.ស.ភ ត្រង់ផ្នែកទី២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ពីទំព័រទី ១០ ដល់ទី១២ |
| **អភិបាលកិច្ចប្រកបដោយចីរភាព** | | |
| ២ | វិធានការ ឬវិធីសាស្ត្រដែល រ.ទ.ស.ភ បាន ឬគ្រោងកំណត់គោលដៅអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាពជាក់លាក់នៅក្នុងយុទ្ធសាស្ត្រអាជីវកម្ម ឬការគ្រប់គ្រងអភិបាលកិច្ច ឬដំណើរការប្រតិបត្តិការរបស់ រ.ទ.ស.ភ | អាជីវកម្មរបស់ រ.ទ.ស.ភ បានអនុវត្តតបតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជាពិសេសស្របទៅតាមគោលដៅទី ៦.១ របស់គោលដៅទី៦ ទឹកស្អាត និងអនាម័យ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព «នៅឆ្នាំ២០៣០ សម្រេចឱ្យបាននូវលទ្ធភាពទទួលបានជាសកល និងស្មើភាពចំពោះទឹកស្អាតដែលមានសុវត្ថិភាព និងតម្លៃសមរម្យសម្រាប់ទាំងអស់គ្នា»។ នេះគឺជាកត្តាកំណត់ដ៏សំខាន់ក្នុងការដឹកនាំផែនការមេលើកទី៣ របស់ រ.ទ.ស.ភ ដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់ឆ្នាំ ២០២១-២០៣០ និងក្នុងការពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម និងបណ្ដាញផ្គត់ផ្គង់ទឹកស្អាតរបស់យើង។ |
| ៣ | ហានិភ័យសំខាន់ៗទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម សម្រាប់រយៈពេលខ្លី មធ្យម ឬវែង ដែល រ.ទ.ស.ភ បានកំណត់អត្តសញ្ញាណហានិភ័យទាំងនេះ ដែលកើតចេញពីប្រតិបត្តិការរបស់ រ.ទ.ស.ភ | កត្តាហានិភ័យសំខាន់ៗ ដែលអាចប៉ះពាល់ដល់ដំណើរការក្នុងការប្រព្រឹត្តកម្មទឹកស្អាត គឺកត្តាបម្រែបម្រួលនៃកម្រិតនីវ៉ូទឹក និងគុណភាពទឹកនាពេលអនាគត។ នៅពេលដែលសីតុណ្ហភាព និងសំណើមកើនឡើង ហើយវដ្តនៃទឹកកាន់តែលឿន ទឹកភ្លៀងក៏កាន់តែខ្លាំង ហើយញឹកញាប់ជាងមុននៅក្នុងខែភ្លៀង និងមិនសូវញឹកញាប់នៅក្នុងខែក្ដៅ។ ប្រការនេះបង្កើតហានិភ័យដែលកម្រិតទឹកក្នុងទន្លេដែល រ.ទ.ស.ភ ប្រើប្រាស់នឹងកើនឡើងខ្ពស់ (ជាមួយនឹងទឹកហូរលឿន) នៅរដូវវស្សា និងទាបជាងនៅរដូវប្រាំង។ វាក៏បង្កើនហានិភ័យរយៈពេលវែងនៃទឹកជំនន់ទន្លេក្នុងរដូវវងា និងទឹកជំនន់ភ្លាមៗនៅរដូវក្ដៅ។<br>ការកើនឡើងនៃកម្ដៅក៏ដូចជាការកើនឡើងនៃតម្រូវការធនធានទឹកស្អាតនៅប្រទេសប៉ែកខាងលើដងទន្លេ ក៏អាចនាំឱ្យមានការកើនឡើងនៃការប្រើប្រាស់ទឹកទន្លេ ដែលនេះជាកត្តាហានិភ័យគួរយកមកពិចារណាផងដែរ។<br>នៅពេលអនាគត រ.ទ.ស.ភ អាចនឹងពិនិត្យឡើងវិញនូវហានិភ័យទាំងនេះ និងសម្រាប់ការបង្កើតនូវសកម្មភាព និងការឆ្លើយតបដែលអាចធ្វើទៅបានទាន់ពេលវេលា។ ការឆ្លើយតបទាំងនោះនឹងមានសារៈសំខាន់ដើម្បីហានិភ័យនាពេលអនាគតដែលបង្ករឡើងដល់ហេដ្ឋារចនាសម្ព័ន្ធរបស់ រ.ទ.ស.ភ និងដើម្បីធានាថា រ.ទ.ស.ភ នៅតែអាចផ្ដល់ឱ្យអតិថិជនរបស់ រ.ទ.ស.ភ ទាំងអស់នូវលទ្ធភាពទទួលបានទឹកស្អាតប្រកបដោយសុវត្ថិភាព និងតម្លៃសមរម្យសម្រាប់ទាំងអស់គ្នា។<br>ព័ត៌មានបន្ថែមមានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០២៤ របស់ រ.ទ.ស.ភ ត្រង់ផ្នែកទី១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ |

| | | |
|---|---|---|
| ៤ | ប្រតិបត្តិការគ្រប់គ្រងហានិភ័យ៖ ដំណើរការដែលត្រូវបានប្រើប្រាស់ដោយ រ.ទ.ស.ភ ក្នុងការកំណត់អត្តសញ្ញាណ និងគ្រប់គ្រងហានិភ័យទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម | នាយកដ្ឋានផែនការ និងគម្រោង បានដឹកនាំសម្រាប់ដំណើរការចងក្រងការវាយតម្លៃទៅលើកត្តាហានិភ័យ និងវិធានការដោះស្រាយ ប្រចាំឆ្នាំសម្រាប់អង្គភាព ដែលរបាយការណ៍នេះត្រូវបានសង្ខេបនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២៤របស់ រ.ទ.ស.ភ ត្រង់ផ្នែកទី១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ ក្រៅពីនេះ យើងពុំមានបទដ្ឋានគ្រប់គ្រងហានិភ័យដាច់ដោយឡែកនោះទេ ហើយកត្តាហានិភ័យទាំងអស់ដែលកើតឡើងត្រូវបានកំណត់អត្តសញ្ញាណដោយប្រតិបត្តិការ ហើយត្រូវបានដោះស្រាយ និងកែតម្រូវលើមូលដ្ឋានដែលកំពុងអនុវត្តបន្ត។ |
| ៥ | យុទ្ធសាស្ត្រ ឬផែនការដែល រ.ទ.ស.ភ អនុវត្តដើម្បីគ្រប់គ្រងហានិភ័យទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម | ដូចដែលបានពិពណ៌នាខាងលើ កត្តាហានិភ័យទាំងនេះត្រូវបានចាត់ទុកជាហានិភ័យរយៈពេលមធ្យម និងរយៈពេលវែងរបស់ រ.ទ.ស.ភ ហើយយើងប្រហែលអាចនឹងពិនិត្យឡើងវិញសម្រាប់ការបង្កើតយុទ្ធសាស្ត្រ និងផែនការដើម្បីគ្រប់គ្រងកត្តាហានិភ័យទាំងនោះ។ ទន្ទឹមនឹងនេះ យើងមានការឆ្លើយតបដែលសមស្របនៃដំណើរការប្រតិបត្តិការប្រចាំថ្ងៃ ដែលមានភាពសាកសមសម្រាប់កត្តាហានិភ័យនាពេលបច្ចុប្បន្ន។ |
| ៦ | អភិបាលកិច្ចនៃហានិភ័យ៖ ដំណើរការអភិបាលកិច្ច និងការរាយការណ៍ដែលត្រូវបានប្រើប្រាស់ដោយក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ ក្នុងការត្រួតពិនិត្យលើហានិភ័យទាក់ទងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម | ក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ កំពុងពិចារណាពង្រីកវិសាលភាពការងាររបស់គណៈកម្មាធិការសវនកម្ម ដើម្បីរួមបញ្ចូលក្នុងការត្រួតពិនិត្យហានិភ័យ។ |
| ៧ | ម៉ាទ្រីស សូចនាករ និងការវាស់វែងសំខាន់ៗ ដែល រ.ទ.ស.ភ ប្រើប្រាស់ក្នុងការតាមដាន និងវាយតម្លៃហានិភ័យទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម | រ.ទ.ស.ភ បានធ្វើការត្រួតពិនិត្យគុណភាពទឹក និងកម្រិតទឹកយ៉ាងសកម្ម ដើម្បីធានាបាននូវគុណភាពទឹកស្អាត បរិមាណទឹកស្អាត និងសម្ពាធទឹក គ្រប់គ្រាន់សម្រាប់អតិថិជនរបស់ខ្លួន។ ក្នុងនោះដែរ អង្គភាពមិនទាន់មានសូចនាករពិសេសដើម្បីតាមដានហានិភ័យរយៈពេលមធ្យមទៅរយៈពេលវែងដូចរៀបរាប់ខាងលើទេ ប៉ុន្តែកំពុងស្ថិតក្នុងការពិចារណា។ |
| ៨ | ហានិភ័យគោលដៅដែល រ.ទ.ស.ភ អនុវត្តក្នុងការគ្រប់គ្រងហានិភ័យទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម និងលទ្ធផលជាក់ស្តែងធៀបនឹងហានិភ័យគោលដៅទាំងនេះ | គោលដៅនៃប្រតិបត្តិការអាជីវកម្មរបស់ រ.ទ.ស.ភ គឺផ្គត់ផ្គង់ទឹកស្អាតជូនអតិថិជន ២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍។ គោលដៅនេះនឹងនាំយើងឱ្យប្រតិបត្តិលើការងារគ្រប់គ្រងហានិភ័យ ពីកម្រិតមធ្យមទៅរយៈពេលវែងដូចដែលបានរៀបរាប់ខាងលើ។ |
| **ផលប៉ះពាល់សង្គម** | | |
| ៩ | ចំនួនម៉ោងនៃវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកម្នាក់ | និយោជិតសរុបមានចំនួន ១.៤៣៤នាក់ ក្នុងនោះនិយោជិតចំនួន៥១៩រូប ទទួលបានការបណ្តុះបណ្តាលសរុប ១៥.១២០ម៉ោង ស្មើនឹង ១០,៥៤ម៉ោង/ម្នាក់។ |
| ១០ | គ្រោះថ្នាក់ការងារ និងអត្រាមរណភាពពេលបំពេញការងារ | ក្នុងឆ្នាំ២០២៤ មានគ្រោះថ្នាក់ការងារកើតឡើងចំនួន ១០ករណីដែលធ្វើឱ្យនិយោជិតរងរបួសចំនួន៨នាក់ និងទទួលមរណភាពចំនួន២នាក់។<br>សេចក្តីសង្ខេបអំពីគ្រោះថ្នាក់ការងារ៖ |

| | | |
|---|---|---|
| | | ▪ ចំនួនគ្រោះថ្នាក់ការងារសរុបៈ ១០នាក់<br>▪ ចំនួននិយោជិតដែលទទួលគ្រោះថ្នាក់សរុប ១០នាក់ក្នុងនោះៈ<br>- របួសស្រាលៈ ៨នាក់(បំពេញការងារ និងគ្រោះថ្នាក់ចរាចរណ៍)<br>- មរណភាពៈ ២នាក់ (ដោយគ្រោះថ្នាក់ចរាចរណ៍ និងបញ្ហាសុខភាព)<br>ការបាត់បង់ជីវិត ពិតជាគួរឱ្យមានភាពសោកស្តាយជាខ្លាំង។ សូមបញ្ជាក់ថា និយោជិតដែលទទួលមរណភាព គឺមិនមែនកើតឡើងនៅពេល ប្រតិបត្តិការការងារទេ ប៉ុន្តែកើតឡើងដោយសារគ្រោះថ្នាក់ចរចរណ៍តាមផ្លូវនៅពេលធ្វើដំណើរទៅបំពេញការងារ និងដោយសារបញ្ហាសុខភាពរបស់បុគ្គលពេលបំពេញការងារក្នុងបរិវេណអង្គភាព។ |
| ១១ | គោលនយោបាយ ឬការប្តេជ្ញារបស់ រ.ទ.ស.ភ ទាក់ទងនឹងការគាំពារកុមារ និងការងារដោយបង្ខំ | រ.ទ.ស.ភ ប្រកាន់ជំហររឹងមាំលើពលកម្មកុមារ លក្ខន្តិកៈបុគ្គលិកដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលតម្រូវឱ្យនិយោជិតមានអាយុយ៉ាងតិច១៨ឆ្នាំទើបអាចមានសិទ្ធិបម្រើការងារបាន ដែលការកំណត់នេះគឺតឹងរ៉ឹងជាងលក្ខខណ្ឌនៃច្បាប់ការងាររបស់ប្រទេសកម្ពុជា ដែលអនុញ្ញាតឱ្យមានការជ្រើសរើសបុគ្គលិកដើម្បីចូលបម្រើការងារចាប់ពីអាយុ១៥ឆ្នាំឡើងទៅ។ |
| ១២ | គោលនយោបាយពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងរួមទាំងបណ្តឹងរបស់បុគ្គលិកចំពោះ រ.ទ.ស.ភ | ទន្ទឹមនឹងនេះ រ.ទ.ស.ភ បានបង្កើតបណ្តាញច្បាស់លាស់ និងងាយស្រួលសម្រាប់ការដាក់សំណើរ ឬបណ្តឹងរបស់អតិថិជន។ ក្នុងនោះដែរ អតិថិជនអាចដាក់សំណើរតាមរយៈ<br>▪ គេហទំព័រហ្វេសប៊ុកផ្លូវការៈ«រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ Phnom Penh Water Supply Authority»<br>▪ ឆាណែលតេលេក្រាមៈ @ppwsa_kh<br>ឬតាមលេខទូរស័ព្ទ +៨៥៥-៣១-៩៣៥-៨០៨០<br><br>សំណើទាំងអស់ដែលទទួលបានតាមរយៈបណ្តាញខាងលើនឹងត្រូវបានកត់ត្រា និងគ្រប់គ្រងជាប្រព័ន្ធទៅតាមនីតិវិធីផ្ទៃក្នុងដើម្បីធានាបាននូវការតាមដានត្រឹមត្រូវ និងការដោះស្រាយឱ្យបានទាន់ពេលវេលា។ បច្ចុប្បន្ន ការងារនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានអាជីវកម្ម។ |
| ១៣ | គោលនយោបាយរបស់ រ.ទ.ស.ភ ពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ | និយោជិតណាម្នាក់ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើពុករលួយ នឹងត្រូវប្រគល់ជូនក្រុមប្រឹក្សាវិន័យរបស់ រ.ទ.ស.ភ។ មានក្រុមប្រឹក្សាវិន័យដែលមានចែងក្នុងលក្ខន្តិកៈបុគ្គលិក និងបានអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីកំណត់វិធានការវិន័យសម្រាប់និយោជិតដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើល្មើស ហើយកម្រិតនៃការដាក់ទណ្ឌកម្ម គឺអាស្រ័យលើភាពធ្ងន់ធ្ងរនៃកំហុសនីមួយៗ។ |
| ១៤ | គោលនយោបាយពាក់ព័ន្ធនឹងការរាយការណ៍ពីកំហុសឆ្គងដោយសម្ងាត់ (Whistle Blowing) | រ.ទ.ស.ភ បានចាត់តាំងឱ្យមានតំណាងនិយោជិត និងបានដំឡើងប្រអប់សំបុត្រនៅតាមអគារ ដែលបានជ្រើសរើសមួយចំនួនសម្រាប់និយោជិតក្នុងការដាក់សំណូមពរ ឬសំណើផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយមិនទាន់មាននីតិវិធីផ្លូវការណាមួយសម្រាប់ពិនិត្យសំណើទាំងនោះទេ។ មូលហេតុ គឺ |

<table>
<tr><td></td><td></td><td>ដោយសារថានៅក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ មិនមានការទទួលបានសំណើណាមួយតាមប្រព័ន្ធប្រអប់សំបុត្រ ឬតំណាងនិយោជិតនោះទេ។</td></tr>
<tr><td>១៥</td><td>សមាមាត្រនៃសមាជិកជាស្ត្រីនៅក្នុងក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ជាស្ត្រី</td><td>
<table>
<tr><th></th><th>ចំនួនសរុប</th><th>ចំនួនស្ត្រី</th><th>ភាគរយស្ត្រីធៀបនឹងចំនួនសរុប</th></tr>
<tr><td>ក្រុមប្រឹក្សាភិបាល</td><td>៨</td><td>០</td><td>០</td></tr>
<tr><td>បុគ្គលិកជាន់ខ្ពស់</td><td>២៧</td><td>៦</td><td>២២%</td></tr>
</table>
</td></tr>
<tr><td>១៦</td><td>ចំនួនបុគ្គលិកសរុបបែងចែកតាមភេទ</td><td>ចំនួនមន្ត្រីនិយោជិតសរុបគិតត្រឹមខែធ្នូ ឆ្នាំ២០២៤៖<br>▪ ចំនួនមន្ត្រីនិយោជិតសរុបមាន ១.៤៣៤រូប។<br>▪ ចំនួនមន្ត្រីនិយោជិតបុរសសរុបមាន ១.១៨៦រូប ស្មើនឹង ៨២,៧% នៃចំនួនមន្ត្រីនិយោជិតសរុប។<br>▪ ចំនួនមន្ត្រីនិយោជិតនារីសរុបមាន ២៤៨រូប ស្មើនឹង ១៧,៣% នៃចំនួនមន្ត្រីនិយោជិតសរុប។</td></tr>
<tr><td>១៧</td><td>គោលនយោបាយពាក់ព័ន្ធនឹងការលើកកម្ពស់ពិពិធកម្មយេនឌ័រ</td><td>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ធានាថានិយោជិតប្រុស និងស្រីទាំងអស់មានសិទ្ធិ និងឱកាសស្មើគ្នានៅកន្លែងធ្វើការ។ ការតែងតាំងតួនាទី និងប្រាក់បៀវត្សរ៍ត្រូវបានកំណត់ដោយផ្អែកលើតួនាទី សមត្ថភាពជំនាញ និងផលិតភាពការងារជាធម្មតាដោយមិនគិតពីភេទឡើយ។ បន្ថែមពីលើនេះទៀត ចំពោះការលើកកម្ពស់សិទ្ធនារី រ.ទ.ស.ភ បានបង្កើត "គណៈកម្មការតំណាងនារី រ.ទ.ស.ភ" ដើម្បីគាំទ្រ និងជម្រុញបន្ថែមដល់និយោជិតនារី។ និយោជិតនារីត្រូវបានលើកទឹកចិត្តឱ្យដាក់សំណើរាយការណ៍ ឬសំណូមពរតាមរយៈតំណាងប្រធាននារីរបស់ខ្លួន ដើម្បីស្វែងរកការប្រឹក្សាយោបល់ និងដោះស្រាយបញ្ហាដែលទាក់ទងនឹងការងារ។<br><br>លើសពីនេះ លក្ខន្តិកៈបុគ្គលិក រ.ទ.ស.ភ ក៏បានចែងអំពីការផ្តល់អត្ថប្រយោជន៍ដល់នារីដូចជាការផ្តល់៖<br>▪ ប្រាក់បៀវត្សរ៍ពេញលេញសម្រាប់ការឈប់សម្រាកសម្រាលកូន រយៈពេល ៣ ខែ។<br>▪ សិទ្ធិក្នុងការចាកចេញពីការងារមុនមួយម៉ោងក្នុងមួយថ្ងៃ រយៈពេលមួយឆ្នាំក្រោយសម្រាល ដើម្បីមើលថែទាំកូន។<br>វិធានការទាំងនេះបង្ហាញ ពីការប្តេជ្ញាចិត្តរបស់ រ.ទ.ស.ភ ក្នុងការលើកស្ទួយបរិយាកាសការងារ ដែលមានភាពស្មើភាព សកម្មភាពរួមបញ្ចូល និងការគាំទ្រដល់និយោជិតនារីទាំងអស់។</td></tr>
</table>

| | | |
|---|---|---|
| ១៨ | ការពិពណ៌នាអំពីគោលនយោបាយ ស្តីពីកិច្ចសហប្រតិបត្តិការជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច | ទឹកស្អាតសម្រាប់ប្រជាពលរដ្ឋចំណូលទាបៈ ដើម្បីរួមចំណែកអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានចាប់ផ្តើមអនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតជូនដល់គ្រួសារមានចំណូលទាប ចាប់តាំងពីឆ្នាំ១៩៩៩ មកម្លេះ។ រ.ទ.ស.ភ បានផ្គត់ផ្គង់ជូនអតិថិជនចំណូលទាបទាំងក្នុង និងក្រៅសហគមន៍តាមរយៈគោលការណ៍ឧបត្ថមធនលើសិទ្ធជាវទឹកគឺ ទទួលបាន ៣០% ៥០% ៧០% និង ១០០% ក្រោមកម្មវិធី "ទឹកស្អាតសម្រាប់ទាំងអស់គ្នា"។<br>បន្ថែមពីនេះ រ.ទ.ស.ភ ក៏បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសប្បុរសធម៌ ដូចជាការបរិច្ចាគថវិកាទៅកាន់មន្ទីរពេទ្យកុមារគន្ធបុប្ផា សមាគមកាកបាទក្រហមកម្ពុជា ជារៀងរាល់ឆ្នាំ និងការសហការកសាងសាលារៀន និងគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតតាមបណ្តាខេត្តនានាទូទាំងប្រទេសកម្ពុជា។ |
| **ផលប៉ះពាល់បរិស្ថាន** | | |
| ១៩ | ការពិពណ៌នាអំពីផលប៉ះពាល់សំខាន់ៗនៃសកម្មភាពអាជីវកម្មរបស់ រ.ទ.ស.ភ ទៅលើបរិស្ថាន | កត្តាប៉ះពាល់សំខាន់ នៃសកម្មភាពអាជីវកម្មរបស់ រ.ទ.ស.ភ រួមមានៈ<br>▪ ទឹកកក់ដែលកើតឡើងពីដំណើរការប្រព្រឹត្តកម្ម<br>▪ កាកសំណល់ពីការវេចខ្ចប់វត្ថុធាតុដើម កាកសំណល់សម្ភារប្រើប្រាស់ចាស់ ឬខូច។ |
| ២០ | ការពិពណ៌នាអំពីគោលនយោបាយស្តីពីការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន នៃសកម្មភាពអាជីវកម្មរបស់ រ.ទ.ស.ភ ទៅលើបរិស្ថាន | គោលនយោបាយស្តីពីការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន នៃសកម្មភាពអាជីវកម្មរបស់ រ.ទ.ស.ភ ទៅលើបរិស្ថានមានដូចជាៈ<br>• ដំណើរការគ្រឿងចក្រដោយប្រើប្រាស់ថាមពលអគ្គីសនី (EDC) និងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ (Solar)។<br>• ប្រើប្រាស់ក្ល័រឧស្ម័ន និងប្រព័ន្ធផលិតក្លរ័រពីអំបិល។<br>• មានការរៀបចំកាត់បន្ថយជាអប្បបរមាដោយការសម្អាត ឬបោះចោលសំណល់រឹង ដូចជាធុងក្លរ័ឧស្ម័ន មានកិច្ចសន្យាជាមួយក្រុមហ៊ុនផ្គត់ផ្គង់ក្នុងការផ្លាស់ប្តូរធុងថ្មី និងទុកដាក់ទីតាំងមានសុវត្ថិភាព។<br>• ប្រើគ្រឿងចក្រដែលមានប្រសិទ្ធភាពខ្ពស់ កាត់បន្ថយការប្រើប្រាស់ថាមពល។<br>• ប្រើប្រាស់គ្រឿងចក្រសម្លេងរំខានទាប។ |
| ២១ | បរិមាណទឹកសរុប ដែលត្រូវបានទាញយកមកប្រើនៅក្នុងប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ | បរិមាណទឹកឆៅសរុបមានចំនួន ៣២៣.៧៤៨.៦៤៣ ម៉ែត្រគូប ដែលត្រូវបានទាញយកមកប្រើនៅក្នុងប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ នៅក្នុងឆ្នាំ២០២៤។ ទឹកឆៅទាំងអស់នេះត្រូវបានទាញចេញពីទន្លេ។ |
| ២២ | សមាមាត្រទឹកកខ្វក់ដែលត្រូវបានបង្កើត សម្អាត និងកែច្នៃឡើងវិញដោយ រ.ទ.ស.ភ | ទឹកកខ្វក់ដែលបានបង្កើតគឺជា ទឹកកខ្វក់ដែលបានកើតឡើងតាមរយៈការប្រើប្រាស់ប្រចាំថ្ងៃ ឬទឹកភ្លៀង ដែលត្រូវបានបង្ហូរចូលទៅក្នុងប្រព័ន្ធលូសាធារណៈ។ |

| | | |
|---|---|---|
| ២៣ | កាកសំណល់រឹងសរុបដែលកើតឡើងចេញពីប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ | កាកសំណល់រឹងសរុបដែលកើតឡើងចេញពីប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ មានដូចជាៈ កាកសំណល់វិចខ្ចប់វត្ថុធាតុដើម បន្ទះផ្ទាំង Solar ដែលបែកខូច និងសម្រាមដែលកើតចេញពីដំណើរការការងាររដ្ឋបាល ត្រូវបានសម្អាតដឹកជញ្ជូនយកទៅដោយក្រុមហ៊ុនប្រមូលសំរាម។ |
| ២៤ | សមាមាត្រនៃសំណល់រឹងដែលបានកែច្នៃ ឬស្តារឡើងវិញដោយ រ.ទ.ស.ភ | ដោយសារមានសំណល់រឹងតិចតួចនៅ រ.ទ.ស.ភ ហើយឱកាសសម្រាប់កែច្នៃឡើងវិញមានកម្រិត។ សំណល់រឹងទាំងអស់ក្នុងឆ្នាំ២០២៤ ត្រូវបានបោះចោលតាមរយៈក្រុមហ៊ុនគ្រប់គ្រងកាកសំណល់ដែលមានអាជ្ញាប័ណ្ណក្រោមអាជ្ញាប័ណ្ណរបស់សហគ្រាសគ្រប់គ្រងសំណល់រឹងទីប្រជុំជនរាជធានីភ្នំពេញ។ |
| **ផលប៉ះពាល់អាកាសធាតុ** | | |
| ២៥ | ផលប៉ះពាល់សំខាន់ៗលើអាកាសធាតុ ដែលបណ្តាលមកពីសកម្មភាពអាជីវកម្មរបស់ រ.ទ.ស.ភ | ការប៉ះពាល់ទៅលើអាកាសធាតុ ដែលបណ្តាលមកពីសកម្មភាពអាជីវកម្មរបស់ រ.ទ.ស.ភ កើតឡើងតាមរយៈការប្រើប្រាស់អគ្គិសនី ដែលបានទិញពីអគ្គិសនីកម្ពុជា និងតាមរយៈប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់បម្រើការងារការដ្ឋាន និងរដ្ឋបាល។ |
| ២៦ | ការពណ៌នាអំពីគោលនយោបាយស្តីពី ការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន នៃសកម្មភាពអាជីវកម្មរបស់ រ.ទ.ស.ភ ទៅលើអាកាសធាតុ | ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន រ.ទ.ស.ភ បានដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យនៅរោងចក្រផលិតទឹកស្អាតចំនួន ៣ ដូចខាងក្រោមៈ<br>• រោងចក្រផលិតទឹកស្អាតភូមិព្រែក<br>• រោងចក្រផលិតទឹកស្អាតបាក់ខែង<br>• រោងចក្រផលិតទឹកស្អាតម្លេច។ |
| ២៧ | បរិមាណថាមពលសរុបដែលត្រូវបានប្រើប្រាស់ក្នុងប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ | បរិមាណថាមពលអគ្គីសនី ដែលត្រូវបានប្រើប្រាស់ក្នុងប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ មានតម្លៃសរុប **៩០.៤៧៩.៥២១kWh** ក្នុងនោះ បានទិញអគ្គិសនីសម្រាប់ដំណើរការផលិតកម្ម ៨៤.១៧២.៥០៩kWh សម្រាប់រដ្ឋបាល ៧៧៤.១៧៨kWh និងអគ្គិសនីសូឡាដែលផលិតដោយ រ.ទ.ស.ភ ៥.៥៣២.៨៣៤kWh។<br><br>ទន្ទឹមនឹងនេះ រ.ទ.ស.ភ បានប្រើប្រាស់ប្រេងសាំងសរុបចំនួន ៦០៨.០៣៤លីត្រ និងប្រេងម៉ាស៊ូតសរុបចំនួន ១.៥៦៤.៤៩៤លីត្រ សម្រាប់បម្រើឱ្យការងាររដ្ឋបាល និងការដ្ឋានប្រចាំថ្ងៃ នៃឆ្នាំ២០២៤។ ដូច្នេះ ប្រសិនយើងបម្លែងទៅជាខ្នាតថាមពល នោះការបរិមាណថាមពលដែលបានប្រើប្រាស់ចេញពីប្រេងឥន្ធនៈ សមមូលនឹងតម្លៃ **២១.៦៨២.០១៧ kWh**។<br><br>ដូច្នេះបរិមាណថាមពលសរុបដែលត្រូវបានប្រើប្រាស់ក្នុងប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ មានតម្លៃសរុបប្រមាណ **១១២.១៦១.៥៣៨ kWh**។ |
| ២៨ | សមាមាត្រ នៃការប្រើប្រាស់ថាមពលកកើតឡើងវិញ នៅក្នុងប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ | សមាមាត្រ នៃការប្រើប្រាស់ថាមពលកកើតឡើងវិញ នៅក្នុងប្រតិបត្តិការនិងអាជីវកម្មរបស់ រ.ទ.ស.ភ គឺប្រមាណ ៥% (៥.៥៣២.៨៣៤kWh/ ៩០.៤៧៩.៥២១kWh)។ |

| | | |
|---|---|---|
| ២៩ | បរិមាណថាមពលសរុបដែលត្រូវបានផលិត និងសមាមាត្រនៃថាមពលកកើតឡើងវិញដែលត្រូវបានផលិតដោយ រ.ទ.ស.ភ | បរិមាណថាមពលសរុបដែលបានផលិតតាមរយៈផ្ទាំង Solar ដែលជាថាមពលកកើតឡើងវិញមានចំនួន ៥.៥៣២.៨៣៤kWh។ |
| ៣០ | វិសាលភាព១៖ ការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ ដោយផ្ទាល់ | ក្នុងឆ្នាំ២០២៤ កន្លងទៅនេះ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ និងអាជីវកម្ម របស់ រ.ទ.ស.ភ ដោយផ្ទាល់ ដែលបានកើតចេញពីការប្រើប្រាស់ឥន្ធនៈ (ប្រេងសាំង និងម៉ាស៊ូត) មានចំនួនសរុបប្រមាណ ៥.៨២៣ $tCO_{2eq}$។ នេះគឺជាការប៉ាន់ស្មានដ៏ល្អបំផុតរបស់យើងដោយផ្អែកលើកត្តាបំភាយ USEPA សម្រាប់ប្រទេសកម្ពុជា។ |
| ៣១ | វិសាលភាព២៖ ការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ ដោយប្រយោល | ក្នុងឆ្នាំ២០២៤ ការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលទាក់ទងនឹងការទិញថាមពលសម្រាប់ប្រតិបត្តិការ និងអាជីវកម្មរបស់ រ.ទ.ស.ភ មានចំនួនប្រមាណ ៥៧.០៨៦ $tCO_{2eq}$។ នេះគឺជាការប៉ាន់ស្មានរបស់យើង ដោយផ្អែកលើកត្តាបំភាយឧស្ម័នដែលបានរួមបញ្ចូលនៅក្នុងការវិភាគឆ្នាំ២០១២ដោយក្រសួងបរិស្ថាននៃប្រទេសកម្ពុជា និងវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសកល (0,៦៧២ $tCO_{2eq}$/MWh)។ |